រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ : ១៣៩៣ សសរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្ដីសម្រេច
# ស្ដីពី
# ការបង្កើតក្រុមការងារអនុវត្តកម្មវិធីអភិបាលកិច្ចមូលដ្ឋាន ដើម្បីសិទ្ធិកុមារ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងប្រកាសលេខ ៤២៧៥ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងសេចក្ដីណែនាំលេខ ០៨២ សណន/គ.ជ.អ.ប ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៧ ស្ដីពីការរៀបចំ និងការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារនៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស

- យោងសេចក្តីណែនាំ ០៥១ សណន/គ.ជ.អ.ប ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការអនុវត្តមុខងាររបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គម ពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅឃុំ សង្កាត់
- យោងផែនការសកម្មភាពប្រចាំឆ្នាំ២០១១ ដែលបានព្រមព្រៀងរវាងយូនីសេហ្វ និងក្រសួងមហាផ្ទៃ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១
- យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ។

## សម្រេច

**ប្រការ ១.-**

បង្កើតក្រុមការងារអនុវត្តកម្មវិធីអភិបាលកិច្ចមូលដ្ឋានដើម្បីសិទ្ធិកុមារ ហៅកាត់ថា "ក្រុមការងារសិទ្ធិកុមារ (ក.ស.ក)" ដើម្បីសម្របសម្រួល និងសហការជាមួយអង្គការយូនីសេហ្វ ដើម្បីធានាដំណើរការនៃការអនុវត្តកម្មវិធីនេះ។

**ប្រការ ២.-**

ក្រុមការងារសិទ្ធិកុមារ មានសមាសភាពដូចខាងក្រោម :

១. ឯកឧត្តម **លេង វី** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ជាប្រធាន
២. លោក **យិន ម៉ាលីណា** ប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ជាអនុប្រធាន
៣. លោក **ខោល យុទ្ធលី** អនុប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន សមាជិក
៤. លោក **សេង សីលា** ប្រធានការិយាល័យផែនការ ស្ថិតិ និងព័ត៌មាន សមាជិក
៥. លោក **យឹម សំអុល** ប្រធានការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន សមាជិក
៦. លោក **គយ ប៊ួយ** អនុប្រធានការិយាល័យហិរញ្ញវត្ថុ សមាជិក
៧. លោក **ជេដ្ឋ គីមផុង** អនុប្រធានការិយាល័យតាមដានត្រួតពិនិត្យ និងគាំទ្រឃុំ សង្កាត់ សមាជិក
៨. លោក **ថេង កន្និ** អនុប្រធានការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន សមាជិក
៩. លោក **ខៀវ ណារ៉ា** មន្ត្រីការិយាល័យផែនការ ស្ថិតិ និងព័ត៌មាន សមាជិក
១០.លោក **ព្រំ ប៊ុនធឿន** មន្ត្រីការិយាល័យអប់រំ និងកសាងសមត្ថភាព សមាជិក
១១.លោក **អ៊ុក សុត្ថា** មន្ត្រីការិយាល័យតាមដាន ត្រួតពិនិត្យ និងគាំទ្រឃុំ សង្កាត់ សមាជិក
១២.លោក **ហោង ប៊ុនលី** មន្ត្រីការិយាល័យស្រាវជ្រាវ និងបច្ចេកទេស សមាជិក
១៣. កញ្ញា **លីម រដ្ឋា** មន្ត្រីការិយាល័យរដ្ឋបាល សមាជិក

**ប្រការ ៣.-**

ក្រុមការងារសិទ្ធិកុមារ មានតួនាទី ភារកិច្ចដូចខាងក្រោម :

- គាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដើម្បីជំរុញ ពង្រឹង

សម្របសម្រួល ពិនិត្យតាមដាន និងវាយតម្លៃនៃការអនុវត្តមុខងារនានា ដែលពាក់ព័ន្ធនឹងការផ្តល់ និងពង្រឹងគុណភាពសេវាសាធារណៈ ជាពិសេស សេវាផ្នែកសង្គម

- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រុមការងារសិទ្ធិកុមារ
- រៀបចំលិខិតបទដ្ឋាន និងគោលការណ៍ណែនាំនានា ពាក់ព័ន្ធបញ្ហាស្ត្រី និងកុមារ សម្រាប់បម្រើឱ្យការអនុវត្តការងារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- សម្របសម្រួលក្នុងការអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យយល់ដឹងអំពីច្បាប់ គោលនយោបាយនានាពាក់ព័ន្ធនឹងការអភិវឌ្ឍផ្នែកសង្គម
- សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន ដើម្បីគាំទ្រ និងផ្តល់ការអប់រំ បណ្តុះបណ្តាល និងកសាងសមត្ថភាពពាក់ព័ន្ធនឹងការអភិវឌ្ឍផ្នែកសង្គមដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល និងសហការជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងការពិនិត្យ តាមដានការទទួល និងប្រើប្រាស់ថវិកាឃុំ សង្កាត់ ដែលគាំទ្រដោយអង្គការ UNICEF
- សហការជាមួយអង្គការ UNICEF និងដៃគូអភិវឌ្ឍន៍នានា ដើម្បីគាំទ្រសកម្មភាពផ្នែកអភិវឌ្ឍសង្គម
- សម្របសម្រួលរៀបចំកិច្ចប្រជុំ ដើម្បីពិនិត្យមើលពីភាពរីកចម្រើន បញ្ហាប្រឈម និងដំណោះស្រាយក្នុងគោលដៅធានាបាននូវការឆ្លើយតប និងប្រសិទ្ធភាពការងារ
- រៀបចំរបាយការណ៍សកម្មភាពរីកចម្រើនប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃដំណើរការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិលើផ្នែកអភិវឌ្ឍសង្គម
- បំពេញភារកិច្ចផ្សេងៗទៀតទាក់ទងផ្នែកអភិវឌ្ឍសង្គម ក្រោមការសម្របសម្រួលរបស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន។

**ប្រការ ៤.-**

ឯកឧត្តម លោក លោកស្រី ដូចមានចែងក្នុងប្រការ២ ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ២០១១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

*កន្លែងទទួល* :

- លេខាធិការដ្ឋាន គ.ជ.អ.ប
- ក្រុមការងារសេវាសង្គមថ្នាក់ជាតិ
- នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន
- នាយកដ្ឋានរដ្ឋបាលទូទៅ
- អង្គការយូនីសេហ្វប្រចាំភ្នំពេញ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ២ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ